

# សន្លឹកព័ត៌មាន យូ.ភី.អ ឆ្នាំ ២០១៩ ប្រទេសកម្ពុជា
# ជុំទីបីនៃការត្រួតពិនិត្យមើលជាសកលតាមកាលកំណត់

SOGIESC-SRHR

## ការរើសអើងផ្នែកសង្គមប្រឆាំងប្រជាជនអ្នកស្រលាញ់ភេទដូចគ្នា LGBTIQ

ការដាក់ជូនរួមគ្នាដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (" CCHR") សហគមន៍ឥន្ទធនូកម្ពុជា ("RoCK") អង្គការគោលដៅយុត្តិធម៌ ("DJ") មីក្រូឥន្ទធនូអន្តរជាតិ ("MRI") អង្គការថែទាំសុខភាពគ្រួសារកម្ពុជា ("RHAC") សមាគមអន្តរជាតិនៃស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស អ្នកស្រឡាញ់ទាំងពីរភេទ អ្នកប្ដូរយេនឌ័រ និងអន្តរភេទនៅអាស៊ី ("ILGA-Asia") ក្រុមការងារអាស៊ានស្ដីពីនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ និងការបង្ហាញនូវទំនោរយេនឌ័រ និងលក្ខណៈភេទ("ASC") សមាគមអប់រំផ្លូវភេទស៊ុយអែត ("RFSU") អង្គការអាក់សិនអេតកម្ពុជា (AAC) ជំនួយរបស់វិហារដាណើម៉ាក ("DCA") និង សមាគមអនាគតយុវជនកម្ពុជា-អាស៊ាន (CamASEAN)។

## ខ្លឹមសារសង្ខេបអំពីបញ្ហាសំខាន់ៗនៅក្នុង យូ.ភី.អ ជុំមុន

ក្នុងអំឡុងពេល យូ.ភី.អ លើកទីពីររបស់កម្ពុជាក្នុងឆ្នាំ ២០១៤ ពុំមានអនុសាសន៍ណាមួយត្រូវបានធ្វើឡើងជូនចំពោះរាជរដ្ឋាភិបាលកម្ពុជា ("RGC") ដោយផ្ដោតជាចំពោះទាក់ទងជាមួយសិទ្ធិរបស់ប្រជាជនជាស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស អ្នកស្រឡាញ់ទាំងពីរភេទ អ្នកប្ដូរយេនឌ័រ អន្តរភេទ និង អ្នកមិនកំណត់ខ្លួនឯងជាក់លាក់ ("អ្នកស្រលាញ់ភេទដូចគ្នា" "LGBTIQ") នោះទេ។

## ក្របខ័ណ្ឌការងារថ្នាក់ជាតិ

ថ្វីបើសហគមន៍ LGBTIQ ក្នុងប្រទេសកម្ពុជាកាន់តែមានភាពលេចធ្លោជាសាធារណៈ អាស្រ័យមួយផ្នែកដោយសារមានចលនាសិទ្ធិ LGBTIQ កាន់តែធំឡើង និងក្នុងបរិបទដែលពុំសូវមានការប្រឆាំងខ្លាំងក្លាផ្នែកសាសនា ឬផ្នែកស្ថាប័នក្ដី ប៉ុន្តែ ប្រជាជន LGBTIQ កម្ពុជានៅបន្តរងការរើសអើង និងត្រូវបានផាត់ចេញពីវិស័យជាច្រើនក្នុងជីវិតសង្គម។ ប្រជាជន LGBTIQ ត្រូវជួបប្រទះការរើសអើងផ្នែកសង្គមក្រោមទម្រង់ជាក់លាក់មួយចំនួន និងការផាត់ចេញពីគ្រួសារ និងសាលារៀន ក៏ដូចជាអំពើហិង្សាផ្នែកយេនឌ័រ ("GBV")។ បន្ថែមលើនេះទៀត ប្រជាជន LGBTIQ ក្នុងប្រទេសកម្ពុជាជួបប្រទះការរើសអើងក្នុងការទទួលបានសេវា និងការរក្សាអាជីពមុខរបរ ក៏ដូចជាការរើសអើង និងការផាត់ចេញនៅកន្លែងធ្វើការ។ បច្ចុប្បន្ន ពុំមានគោលនយោបាយចេញដោយរាជរដ្ឋាភិបាលកម្ពុជា ដើម្បីធានាដល់កិច្ចគាំពារសង្គម និងបរិយាប័ន្នសម្រាប់ប្រជាជន LGBTIQ នៅក្នុងប្រទេសកម្ពុជាទេ។

| បញ្ហាប្រឈម | ផលប៉ះពាល់ |
|---|---|
| **ការរើសអើងពីសមាជិកគ្រួសារ** | **៧៧%** នៃប្រជាជន LGBTIQ និយាយថាពួកគេបានបង្ហាញស្ថានភាពពិតរបស់ខ្លួននៅមានកម្រិត ទៅកាន់មិត្តភក្ដិជិតស្និទ្ធប៉ុណ្ណោះ ហើយ **៥៤%** បង្ហាញប្រាប់តែសមាជិកគ្រួសារបង្កើតប៉ុណ្ណោះ ដោយសារខ្លាចគេរើសអើង វិនិច្ឆ័យ ធ្វើបាប និងបៀតបៀន នៅក្នុងជីវិតប្រចាំថ្ងៃរបស់ខ្លួន។ នៅក្នុងការស្ទាបស្ទង់មតិមួយធ្វើឡើងក្នុងឆ្នាំ ២០១៦ ទៅលើស្ត្រីជាអ្នកប្ដូរយេនឌ័រនៅទីប្រជុំជនបានឱ្យដឹងថាអ្នកផ្ដល់ចម្លើយចំនួន **៥៣,៤៩%** និយាយថា សមាជិកគ្រួសាររបស់ខ្លួនធ្លាប់បានព្យាយាមបង្ខំពួកគេឱ្យរៀបការនាពេលកន្លងមក ហើយ **៤៨,៨៥%** ធ្លាប់មានអារម្មណ៍ថាពួកគេចាំបាច់ត្រូវ**ចាកចេញពីផ្ទះដោយសារតែ SOGIESC**។<br>ក្នុងការស្ទាបស្ទង់មតិមួយធ្វើឡើងក្នុងឆ្នាំ ២០១៥ បានបង្ហាញថា **១៧% នៃឪពុកម្ដាយជាអ្នកស្រលាញ់ភេទផ្ទុយគ្នា** នៅក្នុងការសម្ភាសន៍ បាននិយាយថា ពួកគេនឹង**បង្ខំកូនរបស់ខ្លួន** ឱ្យណាត់ជួបជាមួយមនុស្សភេទផ្ទុយគ្នា ហើយទីបំផុតអាចនឹងបង្ខំពួកគេរៀបការ ដោយមិនអើពើជាមួយការពិតដែលថាអាពាហ៍ពិពាហ៍ដោយបង្ខំគឺជាការបំពានរដ្ឋធម្មនុញ្ញកម្ពុជា។ |
| **ទស្សនៈការមើលឃើញជាទូទៅចំពោះប្រជាជន LGBTIQ** | សេចក្ដីថ្លែងការណ៍ឆ្នាំ ២០១៥ មួយរបស់ក្រសួងព័ត៌មាន**បានអំពាវនាវឱ្យប្រព័ន្ធផ្សព្វផ្សាយបញ្ឈប់ការសើចចំអកចំពោះសហគមន៍ LGBT**។ បន្ទាប់ពីនោះ នៅឆ្នាំ២០១៧ មានការបង្កើត **គណៈកម្មាធិការដើម្បីសង្កេត និងទទួលពាក្យបណ្ដឹង**ពីសវនករដែលមើលឃើញមានខ្លឹមសារបែបរើសអើងនៅក្នុងប្រព័ន្ធផ្សព្វផ្សាយ។<br>**សប្ដាហ៍មោទនភាព ត្រូវបានប្រារព្ធក្នុងប្រទេសកម្ពុជាចាប់តាំងពីឆ្នាំ២០០៩ មក** ដោយមានការបង្ហាញឱ្យឃើញជាសាធារណៈ និងការចូលរួមកាន់តែច្រើនឡើង។ ការស្ទាបស្ទង់មតិរបស់ (CCHR) ក្នុងឆ្នាំ ២០១៧ បានគូសបញ្ជាក់យ៉ាងវិជ្ជមានថាគ្រួសារឥន្ទធនូរាយការណ៍ថាមានការទទួលយកកម្រិតខ្ពស់ពីសហគមន៍របស់ខ្លួន។ ថ្វីបើដូច្នេះក្ដី ប៉ុន្តែ ការរើសអើង និងការផាត់ចេញនៅបន្តជាឧបសគ្គរារាំងមិនឱ្យប្រជាជន LGBTIQ អាចសម្រេចបានសិទ្ធិរបស់ខ្លួនដោយពិតប្រាកដ។ |
| **ការធ្វើបាប និងការផាត់ចេញនៅក្នុងសាលារៀន** | ការស្ទាបស្ទង់មតិមួយក្នុងឆ្នាំ២០១៥ បានបង្ហាញឱ្យឃើញថា **អ្នកផ្ដល់ចម្លើយចំនួន ៦២,៧១% ធ្លាប់ជួបបទពិសោធន៍ការធ្វើបាប** នាពេលមួយក្នុងពេលពួកគេនៅ**សាលារៀន** ហើយ ៩៣,៥៩% នៃអ្នកទាំងនោះមានអារម្មណ៍ថា ការធ្វើបាបនោះអាចបណ្ដាលមួយផ្នែក ឬបណ្ដាលទាំងស្រុងមកពី SOGIESC របស់ពួកគេ។ បន្ថែមពីលើការធ្វើបាបក្នុងទម្រង់ដទៃទៀត គោលនយោបាយឯកសណ្ឋានដែលញែករវាងយេនឌ័រយ៉ាងទូលំទូលាយ ធ្វើឱ្យកុមារ LGBTIQ មានអារម្មណ៍មិនល្អខ្លាំងជាងគេ។<br>ក្នុងឆ្នាំ២០១៥ ក្រសួងអប់រំយុវជន និងកីឡា បានធ្វើការជាដៃគូជាមួយអង្គការក្រៅរដ្ឋាភិបាលនានាដើម្បីរៀបចំ**វគ្គបណ្ដុះបណ្ដាលបញ្ជ្រាបចំណេះដឹងសម្រាប់គ្រូបង្រៀន** ដើម្បីប្រយុទ្ធប្រឆាំងការធ្វើបាបលើយុវជន LGBTIQ។ ក្នុងឆ្នាំ២០១៧ ក្រសួងអប់រំយុវជន និងកីឡា ក្នុងភាពជាដៃគូជាមួយ NGOs បានអភិវឌ្ឍ **កម្មវិធីសិក្សា "បំណិនជីវិត"** ថ្មីមួយដែលត្រូវបានស្នើឡើងដោយផ្ដល់ការបង្រៀនបែបបរិយាប័ន្នស្ដីពីបញ្ហា LGBTIQ ការអប់រំផ្លូវភេទ និងអំពើហិង្សាផ្នែកយេនឌ័រ។ កម្មវិធីសិក្សានេះ មានបំណងទៅជាផ្នែកមួយនៃកម្មវិធីសិក្សាដែលត្រូវរៀនជាកាតព្វកិច្ចនៅតាមសាលារៀនរបស់រដ្ឋ **ហើយគ្រោងនឹងដាក់ឱ្យមាននៅទូទាំងប្រទេសនៅឆ្នាំ ២០២៣**។ |



# សន្លឹកព័ត៌មាន UPR ឆ្នាំ ២០១៨ ប្រទេសកម្ពុជា ជុំទីបីនៃការត្រួតពិនិត្យមើលជាសាកលតាមការកំណត់

## SOGIESC-SRHR

**សិទ្ធិផ្នែកនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ និងការបង្ហាញនូវទំនោរយេនឌ័រ និងលក្ខណៈភេទ (SOGIESC) និង សិទ្ធិសុខភាពផ្លូវភេទ និងសិទ្ធិសុខភាពបន្តពូជ (SRHR) នៅក្នុងប្រទេសកម្ពុជា**

| បញ្ហាប្រឈម | ផលប៉ះពាល់ |
|---|---|
| **អំពើហិង្សាផ្នែកយេនឌ័រ** | ក្នុងឆ្នាំ ២០១៤ ផែនការយុទ្ធសាស្ត្ររយៈពេលប្រាំឆ្នាំរបស់ក្រសួងកិច្ចការនារី បានកត់សម្គាល់ថាស្ត្រីស្រលាញ់ស្ត្រី និងអ្នកប្តូរយេនឌ័រ គឺស្ថិតក្នុងចំណោមក្រុមងាយរងគ្រោះបំផុតនៅក្នុងសង្គម ដែលត្រូវប្រឈមជាមួយហានិភ័យខ្ពស់នៃការរើសអើង ការមាក់ងាយ និងអំពើហិង្សាផ្នែកយេនឌ័រ។<br>ក្នុងការស្ទាបស្ទង់មតិធ្វើឡើងនៅឆ្នាំ២០១៦ បានបង្ហាញថា អ្នកប្តូរយេនឌ័រពីបុរសទៅស្ត្រីចំនួន ៩២% នៅក្នុងការសិក្សានេះធ្លាប់ជួបបទពិសោធន៍ការរំលោភបំពានដោយពាក្យសម្តី ៤៣% ជួបអំពើហិង្សាផ្លូវកាយ ៣១% ជួបការធ្វើបាបផ្លូវភេទ និង ២៥% ជួបការរំលោភសេពសន្ថវៈ។ បន្ថែមលើនេះទៀត អ្នកប្តូរយេនឌ័រពីបុរសទៅស្ត្រីចំនួន ៣៨,៧% នៅក្នុងការស្ទាបស្ទង់មតិធ្វើឡើងដោយ CCHR ត្រូវបាននគរបាលចាប់ខ្លួនយ៉ាងហោចណាស់ម្តង ដោយក្នុងនោះស្ត្រី ៩១,៦៧ ជឿជាក់ថានគរបាលចាប់ខ្លួនពួកគេដោយសារតែអត្តសញ្ញាណយេនឌ័ររបស់ពួកគេ ហើយ ៣៣,៥៨% បានរាយការណ៍ថាខ្លួនធ្លាប់រងការចោទប្រកាន់ដោយខុសឆ្គងថាបានប្រព្រឹត្តិបទល្មើស។ |
| **ការរើសអើងចំពោះលទ្ធភាពទទួលបានមុខរបរ** | ប្រជាជន LGBTIQ ក្នុងប្រទេសកម្ពុជាជួបប្រទះ ការរើសអើងនៅក្នុងការទទួលបាន និងការរក្សាមុខរបរនៃការងាររបស់ខ្លួន ព្រមទាំងការរើសអើង និងការផាត់ចេញនៅកន្លែងធ្វើការ។ ៣៤,៣៥% នៃអ្នកប្តូរយេនឌ័រពីបុរសទៅស្ត្រីទាំងអស់នៅក្នុងការស្ទាបស្ទង់មតិរបស់ (CCHR) ក្នុងឆ្នាំ២០១៦ បានរាយការណ៍ថាធ្លាប់ត្រូវបានគេបដិសេធការងារដោយសារតែខ្លួនជាអ្នកប្តូរយេនឌ័រ ហើយ ២៦,៧២% បានរាយការណ៍ថាធ្លាប់រងការបៀតបៀន ឬធ្វើបាបដោយប្រធាន ឬអ្នករួមការងារដោយសារតែ SOGIE របស់ខ្លួន។ |
| **ស្ថានភាពផ្នែកសេដ្ឋកិច្ចរបស់ប្រជាជន LGBTIQ** | ប្រជាជន LGBTIQ ក្នុងប្រទេសកម្ពុជា**ភាគច្រើនធ្វើការនៅក្នុងវិស័យរងការមើលស្រាលមួយចំនួន** ដែលរារាំងពួកគេមិនអាចគេចចេញពីវដ្តនៃភាពក្រីក្របាន។ ស្ថានភាពនេះត្រូវបានធ្វើឱ្យធុនដាបកាន់តែខ្លាំងឡើងថែមទៀតដោយសារ**ការបដិសេធពីក្រុមគ្រួសារ និងការផាត់ចេញ**នៅសាលារៀន និងក្នុងសហគមន៍ទាំងមូល។ ការសិក្សារបស់ CCHR និងការស្រាវជ្រាវដទៃទៀតក៏បានចង្អុលបង្ហាញ ឱ្យឃើញថាជម្រើសវិស័យការងារដ៏ចង្អៀតបែបនេះ ក៏អាចជាលទ្ធផលកើតចេញពីការកំណត់ខ្លួនឯងជាអ្នកប្តូរយេនឌ័រពីបុរសទៅស្ត្រីដែលបង្កើតឡើងនៅក្នុងបរិបទទូលំទូលាយនៃការរើសអើងផ្នែកសង្គម។ |
| **ការរើសអើងប្រឆាំងអ្នករកស៊ីផ្លូវភេទជា LGBTIQ** | ក្នុងចំណោមអ្នកដែលបានរាយការណ៍ថាខ្លួនធ្លាប់ប្រកបរបរសេវាផ្លូវភេទនាពេលមួយក្នុងពេលកន្លងមក **៩៥,៧៤%** ធ្លាប់រងការបៀតបៀនតាមពាក្យសម្តី **៩១,៣%** រងការធ្វើបាបផ្លូវកាយ និង **៨៥,១១%** រងការធ្វើបាបផ្លូវភេទនៅពេលពួកគេប្រកបរបរសេវាផ្លូវភេទ។ |

## អនុសាសន៍

១. អនុម័តឱ្យមានគោលនយោបាយជាក់លាក់ស្តីពីការមិនរើសអើងដោយឈរលើមូលដ្ឋាន SOGIESC នៅក្នុងសេវាសាធារណៈទាំងអស់របស់រដ្ឋ និងនៅក្នុងនាយកដ្ឋាននគរបាលនៅថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ (អនុលោមតាមគោលដៅអភិវឌ្ឍប្រកដបដោយចីរភាពទី១៦) ត្រឹមឆ្នាំ ២០២០។ *[Rec vii.]*

២. បង្កើតយន្តការការពារកុមារនៅតាមសាលារៀន ដើម្បីធានាឱ្យបានថាគេមានលទ្ធភាពពិនិត្យតាមដាន និងឆ្លើយតបចំពោះការរើសអើងផ្អែកលើ SOGIESC និងអំពើហិង្សា ឱ្យបានមុនឆ្នាំ ២០២០។ *[Rec viii.]*

៣. ធានាឱ្យបានថា សិស្សទាំងអស់ត្រូវបានអនុញ្ញាតិឱ្យជ្រើសរើស ការស្លៀកពាក់ឯកសណ្ឋានសាលារៀនដែលអនុលោមតាមអត្តសញ្ញាណភេទដែលខ្លួនជ្រើសរើស នៅក្នុងប្រព័ន្ធអប់រំរបស់រដ្ឋ និងឯកជន ត្រឹមឆ្នាំ ២០២០។ *[Rec ix.]*

៤. ធ្វើវិសោធនកម្មមាត្រា ១២ នៃច្បាប់ស្តីពីការងារឆ្នាំ ១៩៩៧ ដើម្បីដាក់បញ្ចូលបទបញ្ញត្តិដែលហាមឃាត់ការរើសអើងក្នុងមុខរបរដែលឈរលើមូលដ្ឋាន SOGIESC នៅក្នុងប្រព័ន្ធមុខងារសាធារណៈ និងឯកជន រួមទាំងទាក់ទងនឹងការបណ្តុះបណ្តាលវិជ្ជាជីវៈ ការជ្រើសរើសបុគ្គលិកការតម្លើងឋានៈ ការបណ្តេញចេញពីការងារ ល័ក្ខខ័ណ្ឌមុខរបរ និងការផ្តល់ប្រាក់កម្រៃ ត្រឹមឆ្នាំ ២០២១ អនុលោមតាម SDG ៨.៥។ *[Rec x.]*

៥. អនុវត្តការផ្តួចផ្តើមគំនិតដែលមានគោលដៅដើម្បីជួយធានាសិទ្ធិការងាររបស់ប្រជាជន LGBTIQ រួមទាំងកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈផងដែរ។ *[Rec ix.]*

៦. ធានាឱ្យមានការការពារប្រកបដោយប្រសិទ្ធភាពចំពោះប្រជាជន LGBTIQ ដែលប្រកបរបរសេវាផ្លូវភេទ អនុលោមតាម SDG ៨។ *[Rec xii.]*

- *សូមមើលឯកសារដាក់ជូនរួមគ្នាទាំងស្រុងស្តីពីសិទ្ធិ SOGIESC និង SRHR ដើម្បីអានអនុសាសន៍សព្វជ្រុងជ្រោយទាំងស្រុង។ -

For any inquiries, please contact:
rainbowjustice@destinationjustice.org